ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
មន្ទីរឧស្សាហកម្ម និងសិប្បកម្ម
ខេត្តបន្ទាយមានជ័យ
លេខៈ…………………..ឧបជ

# របាយការណ៍
## ស្តីពីសកម្មភាព និងលទ្ធផលការងារប្រចាំឆ្នាំ ២០១៦
## ផ្នែកទី២
## ការងាររបស់មន្ទីរ អង្គភាពជំនាញ

---

### ២.១. សេដ្ឋកិច្ច

២.១.៤. មន្ទីរឧស្សាហកម្ម និងសិប្បកម្ម

១- ការងារឧស្សាហកម្ម-សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម

មូលដ្ឋានសរុបទូទាំងខេត្តមានចំនួន **៩៥៣ មូលដ្ឋាន**។ មានទុនសរុបមានចំនួន **៦៣.៧៣៩.០០៤ដុល្លារ** ទុនអចល័តមានចំនួន **៤៩.៥៩០.៤៦៧ដុល្លារ** និងមានពលកម្មសរុបចំនួន **៧.៨១៩**នាក់ ក្នុងនោះស្រីមានចំនួន **២,៩៥៤**នាក់ ។

- បើកមូលដ្ឋានអាជីវកម្មថ្មី ចំនួន **៥២** មូលដ្ឋាន(ស្នើសុំថ្មីទៅក្រសួងចំនួន**១៦**មូលដ្ឋាន និង និងចុះបញ្ជីថ្មីនៅមន្ទីរចំនួន **៣៦**មូលដ្ឋាន)
- សុំពន្យាបន្ត **៧៦**មូលដ្ឋាន
- សុំផ្អាកដំណើរការចំនួន ០៣មូលដ្ឋាន
- ធនក្ស័យចំនួន ០០មូលដ្ឋាន
- ទុនសរុបកើនឡើងចំនួន **១៣.៤៦៤.៧៧៩** ដុល្លារ
- ទុនអចល័តកើនមានចំនួន **១០.២៥៥.២៧៩** ដុល្លារ
- ពលកម្មសរុបកើនមានចំនួន **១.០៨៤** នាក់
- ពលកម្មជាស្ត្រីកើនមានចំនួន **១២៧** នាក់

១.១ ឧស្សាហកម្ម

មានរោងចក្រសរុបចំនួន **១១**រោងចក្រ មានទុនសរុប **៤០.៦០៤.៤២៧ ដុល្លារ** ទុនអចល័ត **៣១.២០០.៤២៧ ដុល្លារ** មានពលកម្មសរុប ៣,៨៤៩នាក់ ក្នុងនោះស្រីមានចំនួន ១,៨៤៥នាក់ ។

- **តំបន់សេដ្ឋកិច្ចពិសេសអូរនាង**មានរោងចក្រ ចំនួន០៣ គឺ រោងចក្រកាត់ដេរសម្លៀកបំពាក់ និងរោងចក្រផលិតប្រអប់គ្រឿងអលង្កា ដោយឡែករោងចក្រ ML.Intimate (ទើបបង្កើតថ្មីមិនទាន់មានច្បាប់)។
- **តំបន់សេដ្ឋកិច្ចពិសេសសាន់កូ** មានរោងចក្រចំនួន០៣ គឺរោងចក្រផលិតគ្រឿងឧបករណ៍អេឡិចត្រូនិច រោងចក្រផលិតគ្រឿងបន្លាស់រថយន្ត និងគ្រឿងអគ្គីសនី របស់ក្រុមហ៊ុន ថេកណ ផាក ដោយឡែករោងចក្រ NHK (ទើបបង្កើតថ្មីមិនទាន់ដាក់ពាក្យស្នើសុំច្បាប់នៅឡើយ)។
- រោងចក្រកែច្នៃកៅស៊ូធ្លិន ចំនួន០១ ស្ថិតនៅភូមិគីឡូម៉ែត្រ៤ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត។
- **សួនឧស្សាហកម្មក្រុងសិរីសោភ័ណ** មានរោងចក្រកាត់ដេរសម្លៀកបំពាក់ ចំនួន ០២ រោងចក្រ ។
- រោងចក្រកិនស្រូវ BAKAVA (ឥណ្ឌា) ចំនួន០១ ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ។
- រោងចក្រកិនស្រូវ កូរ៉េ ចំនួន០១ ស្ថិតនៅភូមិរហាល ឃុំរហាល ស្រុកព្រះនេត្រព្រះ ។

**១.២ សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម**

មានមូលដ្ឋានសរុបចំនួន **៩៤២ មូលដ្ឋាន** មានទុនសរុប **ចំនួន២៣.១៣៤.៥៧៧ដុល្លារ** មានទុនអចល័ត **ចំនួន ១៨.៣៩០.០៤០ដុល្លារ** មានពលកម្មសរុប ៣,៩៧០នាក់ ក្នុងនោះស្រីមានចំនួន ១,១០៩នាក់។

- ការិយាល័យបានរៀបចំផែនការចុះជំរុញសិប្បករ-អាជីវករឲ្យមកចុះបញ្ជីជាបន្តបន្ទាប់ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។
- បានចុះយកគំរូទឹកពិសាជបទៅវិភាគគុណភាពនៅមជ្ឈមណ្ឌលពិសោធន៍ឧស្សាហកម្មកម្ពុជាចំនួន០៤ មូលដ្ឋាន។
- ចុះចែកសេចក្ដីជូនដំណឹងស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ប្រកាសស្ដីពីនីតិវិធី បែបបទ ស្នើសុំបង្កើតរោងចក្រ និងសិប្បកម្ម និងបទបញ្ញាស្ដីពីរបបរាយការណ៍ ដែលត្រូវផ្ដល់ឲ្យមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ដើម្បីធានាបាននូវសុខុមាលភាពសាធារណៈ បរិស្ថាន និងសង្គម។
- ការិយាល័យបានចុះណែនាំម្ចាស់សិប្បកម្មផលិតទឹកពិសាជបក្នុងក្រុងសិរីសោភ័ណអោយរៀបចំផ្លាកយីហោសិប្បកម្មអោយបានត្រឹមត្រូវស្របតាមប្រកាសស្ដីពីការបង្កើតរោងចក្រ និងសិប្បកម្ម។
- ការិយាល័យបានចុះណែនាំម្ចាស់សិប្បកម្មផលិតទឹកពិសាជបក្នុងក្រុងប៉ោយប៉ែតអោយរៀបចំផ្លាកយីហោសិប្បកម្មអោយបានត្រឹមត្រូវ អោយពង្រឹងគុណភាព និងអនាម័យល្អ ដើម្បីធានានូវសុខមាលភាពជូនប្រជាពលរដ្ឋ
- ចូលរួមជាមួយគណៈកម្មការខេត្តចុះដោះស្រាយផលប៉ះពាល់រោងម៉ាស៊ីនសម្ងួតស្រូវរបស់លោក ឌី ឆាយ លើប្រជាពលរដ្ឋនៅក្នុងឃុំភ្នំតូច ស្រុកមង្គលបូរី។
- ចែកលិខិតអញ្ជើញអាជីវករ សិប្បករក្នុងខេត្តអោយទៅចូលរួមសិក្ខាសាលា ស៥ នៅខេត្តសៀមរាប
- ចែកលិខិតអញ្ជើញអាជីវករ-សិប្បករ អោយចូលរួមប្រជុំផ្សព្វផ្សាយស្ដីពីវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត។
- ការិយាល័យបានចុះណែនាំម្ចាស់សិប្បកម្មផលិត ទឹកពិសាជប ក្នុងក្រុងប៉ោយប៉ែតដែលមានប្រកាសអនុញ្ញាតអោយដាក់ពាក្យស្នើសុំវិញ្ញាបនបត្រដំណើរចំនួន ០៥មូលដ្ឋាន និងដាក់លិខិតអញ្ជើញសិប្បកម្ម

ផលិតទឹកពិសាដបដែលគ្មានច្បាប់អនុញ្ញាត ០១ មូលដ្ឋាន អោយមកដាក់ពាក្យសុំប្រកាសអនុញ្ញាតទៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម តាមរយៈមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត។

- បានដាក់លិខិតអញ្ជើញម្ចាស់សិប្បកម្មបេតុងលាយស្រេចក្នុងក្រុងសិរីសោភ័ណ ០១មូលដ្ឋាន ដែលមិនទាន់មានវិញ្ញាបនបត្រអនុញ្ញាតដំណើរការនៅឡើយ។
- បានចុះត្រួតពិនិត្យខ្សែសង្វាក់ផលិតកម្មផលិតទឹកកកព្រិល របស់លោកស្រីដួង ដារី ដែលមានទីតាំងស្ថិតក្នុងភូមិអូរស្ងួត ឃុំអូរប្រាសាទ ដើម្បីធានាអោយបាននូវសុខសុវត្ថិភាពជូនសាធារណៈជន និងបានដាក់លិខិតអញ្ជើញម្ចាស់រោងម៉ាស៊ីនកិនស្រូវ លោកប៉ែនផល លោកចូយ ទិញ លោកចៅ ម៉ី លោកស្រីចៅ ស៊ីវ និងលោកស្រីស្រេង កល្យាណី អោយមកដាក់ពាក្យស្នើសុំបន្តវិញ្ញាបនបត្រដំណើរការសិប្បកម្មឡើញវិញ នាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦។
- បានចុះត្រួតពិនិត្យបំពេញលិខិតសុវិជាន-អសុវិជានសិប្បកម្មផលិតទឹកក្រូចព្រិល របស់លោកស្រីដួង ដារី ដែលមានទីតាំងស្ថិតក្នុងភូមិអូរស្ងួត ឃុំអូរប្រាសាទ និងបានដាក់លិខិតអញ្ជើញម្ចាស់រោងម៉ាស៊ីនកិនស្រូវ លោក ឡុង ពុន លោក ជឹង ទី លោក កៅ និមល លោក ហី លិញ លោកស្រី ឡុង ង៉ា អោយមកដាក់ពាក្យស្នើសុំបន្តវិញ្ញាបនបត្រដំណើរការសិប្បកម្មឡើញវិញ។
- បានយកវិញ្ញាបនបត្រដំណើរការសិប្បកម្មបន្តជូនរោងម៉ាស៊ីនកិនស្រូវ លោក ឡុង ពុន លោក ជឹង ទី លោក ចូយ ទិញ លោកស្រី ឡុង ង៉ា និងបានដាក់លិខិតអញ្ជើញម្ចាស់សិប្បកម្មចំនួន០៩ មូលដ្ឋានក្នុងនោះមានដូចជា៖ លោក ចៅ ម៉ី លោក ជឹង ទី លោកកៅ និមល លោក ហាន់ ហិញ លោក យូ គី សុខ លោក ស៊ុន ហេងវ៉ាត់ លោក រី ដារ៉ាត់ លោក ហ៊ិន ភាស់ លោក ជាង ដេត អោយមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្របន្ត និង ដាក់ពាក្យស្នើសុំចុះបញ្ជីថ្មី នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦។
- បានចុះដាក់លិខិតអញ្ជើញសិប្បកម្ម ទ្វារដំបូលបង្អួចដែក កែច្នៃស័ង្កសី កែច្នៃទូកញ្ចក់ និងរោងជាងក្រឡឹង ចំនួន ០៥ មូលដ្ឋាន ក្នុងក្រុងសិរីសោភ័ណ្ឌ អោយមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្របន្ត និងចុះបញ្ជីថ្មី។
- បានយកវិញ្ញាបនបត្រដំណើរការសិប្បកម្មបន្ត/ថ្មីជូនម្ចាស់សិប្បកម្មទ្វារដំបូលបង្អួចដែក និងរោងម៉ាស៊ីនកិនស្រូវ លោក ចៅ ម៉ី លោក ជឹង ទី លោកកៅ និមល លោក ហាន់ ហិញ លោក យូ គី សុខ លោក ស៊ុន ហេងវ៉ាត់ លោក រី ដារ៉ាត់ លោក ហ៊ិន ភាស់ និងបានដាក់លិខិតអញ្ជើញម្ចាស់សិប្បកម្មចំនួន ០៧មូលដ្ឋាន ក្នុងនោះមានដូចជា៖ លោក ឆាយ គឹមតឹង លោក ភាគ ឈួយ លោក មួរ សាវុធ លោកស្រី ង៉ាន់ ឡាយ លោក ម៉ាប់ ម៉ៅ លោក លឿង ថៃលី លោក ខន ងន់ស្រេង អោយមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្របន្ត និង ដាក់ពាក្យស្នើសុំចុះបញ្ជីថ្មី នាថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៦។
- បានចុះដាក់លិខិតអញ្ជើញសិប្បកម្មម៉ាស៊ីនកិនស្រូវ លោកលឹម ម៉េង អោយមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្របន្ត និងរៀបចំលិខិតផ្ទេរសិទ្ធិម៉ាស៊ីនកិនស្រូវលោកមួរ សាវុធ ផ្ទេរសិទ្ធិអោយ រុន ចាន់ណួយត្រូវជាកូន នាថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១៦។
- បានយកវិញ្ញាបនបត្រដំណើរការសិប្បកម្ម ជូនលោក មួរ សាវុធ លោកម៉ាប់ ម៉ៅ លោកលឿង ថៃលី លោក ខន ងន់ស្រេង ។

- បានចុះត្រួតពិនិត្យសំណើរសុំបង្កើតរោងចក្រធុនតូចកែច្នៃសំណល់អាលុយមីញ៉ូមរបស់ក្រុមហ៊ុន គ្លូបិល អាលុយមេធល.ឯក នៅថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៦ (ក្រុមការងារមន្ទីរឧស្សាហកម្ម និងសិប្បកម្ម , សហការជាមួយក្រុមអធិការកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រុមការងារក្រសួងបរិស្ថាន។
- ចុះចែកវិញ្ញាបនបត្រដំណើរការម៉ាស៊ីនកិនស្រូវលោក ឆាយ គឹមទឹង លោកភាគ ឈួយ លោកស្រីង៉ាន់ ឡាយ លោកស្រីចៅ នុយ និងលោកលឹម ម៉េង នៅក្នុងស្រុកមង្គលបូរី។
- ចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ស្តីអំពីការស្រាវជ្រាវអំពីពាណិជ្ជកម្ម និងការបង្កើតទិន្ន័យពាណិជ្ជកម្ម នៅវិទ្យាស្ថានមេគង្គប្រទេសថៃចាប់ពីថ្ងៃទី១៤-១៨ ខែវិច្ឆកា ឆ្នាំ២០១៦។
- ចុះយកសំណាកគំរូផលិតផលចំណីអាហារចំនួន ២០មូលដ្ឋាន (សាច់ក្រក គុយទាវ នំ ណែម ) យកទៅវិភាគគុណភាពនៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា។
- ការិយាល័យបានរៀបចំផែនការចុះជំរុញសិប្បករ-អាជីវករឲ្យមកចុះបញ្ជីជាបន្តបន្ទាប់ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**២- ការងារទឹកស្អាត**

ក្រុមហ៊ុនផលិត និងផ្គត់ផ្គង់ទឹកស្អាតមានចំនួន ១០មូលដ្ឋាន

- ចំនួននាឡិកាសរុប **២៩.១៥០** នាឡិកា
- បរិមាណទឹកផលិតបាន **៧.៩២៤.១៤០** ម៉ែត្រគូប
- បរិមាណទឹកលក់បាន **៦.១២៦.០១៧** ម៉ែត្រគូប
- បរិមាណទឹកបាត់បង់ **១.៧៩៨.១២៣** ម៉ែត្រគូប ស្មើនឹង **២២,៧%**

- ចុះពិនិត្យការងាររដ្ឋាករទឹកឯកជន និងក្រុមហ៊ុនយុនអភិវឌ្ឍន៍នៅក្នុងក្រុងសិរីសោភ័ណប្រមូលរបាយការណ៍ផលិត និងចែកចាយទឹកស្អាតជូនអតិថិជនប្រចាំខែ និងត្រីមាសយកទៅវិភាគរាល់បីខែម្តង ។
- បានចុះត្រួតពិនិត្យក្រុមហ៊ុននិងសេវាករផ្គត់ផ្គង់ទឹកស្អាតទូទាំងខេត្តជាមួយគណៈប្រតិភូកម្មមកពីក្រសួង
- ចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រងទឹក និងការគណនាទឹកដែលបាត់បង់ នៅបាត់ដំបង នាថ្ងៃទី ១៩-២៣ ខែកញ្ញា ឆ្នាំ២០១៦។
- ចូលរួមដោះស្រាយបញ្ហាដីរោងចក្រទឹកស្អាតនៅស្រុកភ្នំស្រុក នាថ្ងៃទីនាថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៦។
- បន្តចុះជំរុញបណ្តារដ្ឋាករទឹកឯកជនក្នុងខេត្តអោយខិតខំបង្កើនចំនួនអតិថិជន កាត់បន្ថយការបាត់បង់ទឹកក្នុងផលិតកម្ម និងលើកកំពស់គុណភាពទឹកនិងបង្កើនប្រសិទ្ធិភាពផ្គត់ផ្គងដល់អតិថិជន។

### ៣- ការងារស្តង់ដារ និងមាត្រាសាស្ត្រ

❖ មូលដ្ឋានអាជីវកម្មដែលប្រើឧបករណ៍មាត្រាសាស្ត្របានចូលមកចុះបញ្ជីនៅចក្រចេញចូលតែមួយនៅ ម-ម-ជ ពីខែមករា រហូតដល់ ខែធ្នូ ឆ្នាំ២០១៦ បានសរុប **១៤២** មូលដ្ឋានរួមមាន៖

- ❖ ស្ថានីយ៍ប្រេងចំនួន ៨១មូលដ្ឋាន
- ❖ ទឹកពិសាជបចំនួន ២៦មូលដ្ឋាន
- ❖ ម៉ាស៊ីនកិនស្រូវចំនួន ៣០មូលដ្ឋាន
- ❖ ដេប៉ូហ្គាសចំនួន ០៣មូលដ្ឋាន
- ❖ ទឹកស៊ីអ៊ីវចំនួន ០១មូលដ្ឋាន
- ❖ អគ្គីសនីចំនួន ០១មូលដ្ឋាន

- បានចុះចែកលិខិតអញ្ជើញ សិប្បករ-អាជីវករ ដែលជាម្ចាស់ស្ថានីយ៍ប្រេង និងកន្លែងលក់ប្រេងឲ្យមកបំពេញបែបបទនិងដាក់ពាក្យស្នើសុំត្រួតពិនិត្យដៃបាញ់ប្រេងនិងម៉ាស៊ីនបែងចែកប្រេងបានចំនួន ៩៣មូលដ្ឋាន ។
- អាជីវករបានចូលមកបំពេញបែបបទ និងដាក់ពាក្យស្នើសុំត្រួតពិនិត្យឧបករណ៍មាត្រាសាស្ត្រដៃបាញ់ប្រេងសរុប ៥៨៥ដៃម៉ាស៊ីនបែងចែកប្រេងសរុប ១៩០គ្រឿង ហើយអាជីវករ សិប្បករបានបង់សេវាត្រួតពិនិត្យទៅតាម ប្រកាសអន្តរក្រសួងលេខ ៧១៧ សហវ/ប្រក ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

❖ ឧបករណ៍ស្តង់ដារប្រេត្តិបត្ត

| | | |
|---|---|---|
| ១-កូនទម្ងន់ខ្នាត | ២០គក | ចំនួន ០៤គ្រាប់ |
| ២-កូនទម្ងន់ខ្នាត | ១០គក | ចំនួន ០១គ្រាប់ |
| ៣-កូនទម្ងន់ខ្នាត | ០១គក | ចំនួន ០២គ្រាប់ |
| ៤-កូនទម្ងន់ខ្នាត | ១/២គក | ចំនួន ០១គ្រាប់ |
| ៥-កូនទម្ងន់ខ្នាត | ១/៤គក | ចំនួន ០១គ្រាប់ |
| ៦-កូនទម្ងន់ខ្នាត៥មីលីក្រាម | ០១គក | ចំនួន ០១ឈុត |
| ៧-កែវក្រិត | ចំណុះ៥L | ចំនួន ០២គ្រឿង |
| ៨-កែវក្រិត | ចំណុះ០១L | ចំនួន ០១គ្រឿង |
| ៩-កែវក្រិត | ចំណុះ១/២L | ចំនួន ០១គ្រឿង |

- បានចុះយកសំណាកគំរូផលិតផលស្រាស ០៦មូលដ្ឋាន មញ្ជូនទៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ។
- បានចុះយកសំណាកគំរូផលិតផលទឹកពិសាជប ០៩មូលដ្ឋាន មញ្ជូនទៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ។
- ចុះចែកសេចក្តីជូនដំណឹងលេខ ១៩MIH/2016 ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ និងសេចក្តីជូនដំណឹងលេខ ១៩៦MIH/2016 ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

- បានចុះអមដំណើរជាមួយក្រុមការងារវិទ្យាស្ថានស្តង់ដារកម្ពុជា ចាប់ពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦។
- បានចូលរួមវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានស្តង់ដារកម្ពុជា ចាប់ពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៦។
- បានចូលរួមសិក្ខាសាលាស្តីពីការប្រមូលពត៏មាននិងប្រមូលទិន្ន័យនៅខេត្តបាត់ដំបង ចាប់ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ ។
- បានចូលរួមវគ្គបណ្តុះបណ្តាលទំនិញវេចខ្ចប់នៅភ្នំពេញចាប់ពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៦ ដល់ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ ។
- ចុះស្រង់ស្ថិតិ មូលដ្ឋានអាជីកម្ម សិប្បកម្ម ដែលពាក់ព័ន្ធនិងផ្នែកមាត្រាសាស្ត្រដែលទើបបង្កើតថ្មី និងមូលដ្ឋានចាស់ដែលក្ស័យធន់
- ចុះស្រង់ស្ថិតិជញ្ជីងស្ពាន
- ចុះចែកសេចក្តីជូនដំណឹងដល់សិប្បករ អាជីវករដែលជាម្ចាស់ស្ថានីយ៏ឲ្យចូលមកបំពេញបែបបទ និងដាក់ពាក្យស្នើសុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧
- រៀបចំផែនការណ៏ត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៏មាត្រាសាស្ត្រទូទាំងខេត្ត
- ចុះយកសំណាកគំរូផលិតផលទៅមន្ទីរពិសោធន៍
- បន្តបញ្ជាបលិខិតបទដ្ឋានគតិយុត្ត ច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា និងច្បាប់ស្តីពីស្តង់ដារកម្ពុជា ដល់សិប្បករ អាជីវករ ដែលជាម្ចាស់សិប្បកម្ម អាជីវកម្មឲ្យចូលរួមអនុវត្តច្បាប់ដែលមានជាធរមាន។

**៤- ការងារផ្សេងៗ**

- ទទួលបដិសណ្ឋារកិច្ច ឯកឧត្តម ហេង សុខគង់ រដ្ឋលេខាធិការ និងប្រតិភូអមដំណើរ នៃក្រសួងឧស្សាហាកម្ម និងសិប្បកម្ម
- ថ្ងៃទី១៧-១៩ ខែឧសភា ឆ្នាំ២០១៦ ចូលរួមយុទ្ធនាការសម្តេចតេជោចែកទឹកជូនប្រជាពលរដ្ឋរងគ្រោះដោយភាពរាំងស្ងួត ក្នុងខេត្តបន្ទាយមានជ័យ ក្រោមការឧបត្ថមរបស់ក្រុមហ៊ុនស្រាបៀអង្គរដែលបានឧបត្ថមទឹកពិសាដបអង្គរព្យូ៉ ចំនួន៥០០០កេស និងឡានដឹកទឹកស្អាតចែកជូនប្រជាពលរដ្ឋចំនួន ០៧ គ្រឿង តាមរយៈក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលមានសមាសភាពថ្នាក់ដឹកនាំក្រសួង និងមន្ត្រីនៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តចូលរួមមានដូចខាងក្រោម៖

  -លោកជំទាវ ឡាយ ណារីន រដ្ឋលេខាធិការ និងគណៈប្រតិភូអមអំណើរ មន្ត្រីមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត បុគ្គលិកក្រុមហ៊ុនស្រាបៀអង្គរ និងអាជ្ញាធរមូលដ្ឋាន បានចុះចែកទឹកស្អាតជូនប្រជាពលរដ្ឋក្នុងស្រុកព្រះនេត្រព្រះ ចំនួន ៦៨ម៉ែត្រគូប និងទឹកពិសាដបអង្គរព្យូ៉ចំនួន១,០០០កេស មានបីឃុំ គឺឃុំឈ្នូរមានជ័យ(ភូមិពង្រ គោកត្រាច រពាក់ គោកទ្រាស់ សំរោងតូច ឬស្សីកណ្តាល មានចំនួនគ្រួសារ ៨២២គ្រួសារ) និងឃុំបុស្បូវ(ភូមិបុស្បូវ ត្របែក កណ្តាល គោកធំ សូត្រមន្ត មានចំនួនគ្រួសារ ៨៣៧គ្រួសារ)និងឃុំភ្នំលៀប។

-ឯកឧត្តម សយ ភីរម្យ អនុរដ្ឋលេខាធិការ និងមន្ត្រីមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត បុគ្គលិកក្រុមហ៊ុនស្រាបៀរអង្គរ និងអាជ្ញាធរមូលដ្ឋាន បានចុះចែកទឹកស្អាតជូនប្រជាពលរដ្ឋក្នុងស្រុកស្វាយចេក ចំនួន ២០៨ម៉ែត្រគូប និងទឹកពិសាដបអង្គរពូរ៉ូចំនួន១,០០០កេស មានបីឃុំ គឺឃុំស្វាយចេក(ភូមិថ្មី និងភូមិស្លែង មានចំនួនគ្រួសារ ១៨៦គ្រួសារ) ឃុំតាបែន(ភូមិតាបែន គោកតាឯក គោករកាមានចំនួនគ្រួសារ ៣០៧គ្រួសារ) និងឃុំស្លក្រោម(ភូមិកំណប់ និងភូមិក្លែងព័ណ មានចំនួនគ្រួសារ ៤៤៨គ្រួសារ)

-ឯកឧត្តម អ៊ុំ សុថា អនុរដ្ឋលេខាធិការ និងមន្ត្រីមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត បុគ្គលិកក្រុមហ៊ុនស្រាបៀរអង្គរ និងអាជ្ញាធរមូលដ្ឋាន បានចុះចែកទឹកពិសាដបអង្គរពូរ៉ូចំនួន១,០០០កេសជូនប្រជាពលរដ្ឋក្នុងស្រុកម៉ាឡៃ ក្នុងឃុំទួលពង្រ។

-ឯកឧត្តម សឹម ណារ៉ា អគ្គនាយកដ្ឋានឧស្សាហកម្ម និងមន្ត្រីមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត បុគ្គលិកក្រុមហ៊ុនស្រាបៀរអង្គរ និងអាជ្ញាធរមូលដ្ឋាន បានចុះចែកទឹកស្អាតជូនប្រជាពលរដ្ឋក្នុងស្រុកមង្គលបូរី ចំនួន ១០០ម៉ែត្រគូប និងទឹកពិសាដបអង្គរពូរ៉ូចំនួន១,០០០កេស មានឃុំហាត់ទឹក (ភូមិកស្វាយ អូរជង្កោ ចំការចេក មានចំនួនគ្រួសារ ៩៣៤គ្រួសារ) និង មន្ទីរពេទ្យបង្អែកស្រុកមង្គលបូរី។

-មន្ត្រីមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត បុគ្គលិកក្រុមហ៊ុនស្រាបៀរអង្គរ និងអាជ្ញាធរមូលដ្ឋាន បានចុះចែកទឹកពិសាដបអង្គរពូរ៉ូចំនួន១,០០០កេស និងទឹកស្អាតជូនប្រជាពលរដ្ឋក្នុងស្រុកអូរជ្រៅចំនួន ១៦ម៉ែត្រគូបក្នុងឃុំអូរបីជាន់។

-មន្ត្រីមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត បុគ្គលិកក្រុមហ៊ុនស្រាបៀរអង្គរ និងអាជ្ញាធរមូលដ្ឋាន បានចុះចែកទឹកស្អាតជូនប្រជាពលរដ្ឋនៅស្រុកថ្មពួកចំនួន ៣២ម៉ែត្រគូបក្នុងភូមិទ័ពសៀម។

- ក្នុងយុទ្ធនាការចែកទឹកសម្តេសតេជោរយៈពេលបីថ្ងៃនេះរដ្ឋាករទឹក និងក្រុមហ៊ុនសេវាករផ្គត់ផ្គង់ទឹកស្អាត បានឧបត្ថមទឹកស្អាតមានដូចខាងក្រោម៖

-រដ្ឋាករទឹកខេត្តបាត់ដំបងបានឧបត្ថមទឹកស្អាតចំនួន ១១៤ ម៉ែត្រគូប

-ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតក្រុងសិរីសោភ័ណបានឧបត្ថមទឹកស្អាតចំនួន ១៦០ ម៉ែត្រគូប

-ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតក្រុងប៉ោយប៉ែតបានឧបត្ថមទឹកស្អាតចំនួន ១១៤ ម៉ែត្រគូប

-ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតស្រុកមង្គលបូរីបានឧបត្ថមទឹកស្អាតចំនួន ២០ ម៉ែត្រគូប

-ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតស្រុកព្រះនេត្រព្រះបានឧបត្ថមទឹកស្អាតចំនួន ១៧ ម៉ែត្រគូប

- ចូលរួមយុទ្ធនាការចែកទឹកពិសាដបអង្គរពូរ៉ូចំនួន ៥.០០០កេះ ដែលជាអំណោយរបស់ក្រុមហ៊ុនស្រាបៀរអង្គរតាមរយៈ **ឯកឧត្តម ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជូនដល់ប្រជាពលរដ្ឋចំនួន ០៨ស្រុក/ក្រុងបន្ថែមទៀត នាថ្ងៃទី២៦ ខែសីហា រហូតដល់ថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១៦

- ចូលរួមកាត់ឯកសណ្ឋានមន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រ នៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នាថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៦។
- ចូលរួមសិក្ខាសាលា ស្តីពីការពង្រឹងការអនុវត្តបទបញ្ញត្តិក្នុងការផលិត និងការចរាចរអំបិលអ៊ីយ៉ូតនៅកម្ពុជា នាថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៦។
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការផ្ទេរមុខងារ និងធនធានអោយទៅរដ្ឋបាលថ្នាក់ក្រោមជាតិ នាថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៦។
- ចូលរួមប្រជុំបូកសរុបការងារជនពិការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ និងលើកទិសដៅបន្ត នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦។
- ចូលរួមប្រជុំបូកសរុបការងារប្រចាំឆ្នាំ និងលើកទិសដៅបន្តសម្រាប់ក្រុមការងារដើម្បីកុមារ នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦។

## ផ្នែកទី៣
## បញ្ហាប្រឈមមុខ និងដំណោះស្រាយ

### ៣.២. មន្ទីរអង្គភាពជំនាញ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើរដំណោះស្រាយ |
|---|---|---|
| ១៤).មន្ទីរឧស្សាហកម្ម និងសិប្បកម្ម | | |
| ១ | -ខ្វះធនធានមនុស្ស និងមន្ត្រីបច្ចេកទេសក្នុងការបំពេញតួនាទីភារកិច្ចស្នូលរបស់អង្គភាព | - ស្នើរសុំរដ្ឋបាលខេត្ត ក៏ដូចជាក្រសួងមេត្តាជ្រើសរើសមន្ត្រីបន្ថែមតាមការចាំបាច់។<br>- សូមវិទ្យាស្ថានស្តង់ដារកម្ពុជាជួយបណ្តុះ បណ្តាលមន្ត្រីទទួលបន្ទុក និងត្រួតពិនិត្យការងារនេះ អំពីនិតិវិធីអនុវត្តន៍ ។<br>- សូមឲ្យមានការបញ្ជូនមន្ត្រីរាជការបានចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលា និងវគ្គផ្សេងៗសំដៅលើកកំពស់សមត្ថភាពវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈឲ្យសមស្របតាមសភាពការ វិវត្តន៍នៃសង្គម។ |
| ២ | -ខ្វះឧបករណ៍ស្តង់ដារមាត្រាសាស្ត្រ | - ស្នើសុំវិទ្យាស្ថានស្តង់ដារកម្ពុជា និងមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិជួយផ្តល់ឧបករណ៍ស្តង់ដារមាត្រាសាស្ត្រជូនដល់មន្ទីរ ដើម្បីបានចុះអនុវត្តការងារ |

| | | |
|---|---|---|
| | | ប្រកបដោយប្រសិទ្ធភាព។ |
| ៣ | -ខ្វះមធ្យោបាយធ្វើដំណើរសម្រាប់ចុះបំពេញភារកិច្ចការងារក្នុងម៉ោងរដ្ឋបាល | -ស្នើសុំរដ្ឋបាលខេត្ត ក៏ដូចជាក្រសួងមេត្តាសម្រួលបើកផ្តល់មធ្យោបាយដោយក្តីអនុគ្រោះ។ |
| ៤ | -ការចុះធ្វើបច្ចុប្បន្នភាពរោងចក្រសិប្បកម្មតាមបណ្តាភូមិឃុំស្ថិតនៅឆ្ងាយៗ | -សំណូមពរប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់បំពេញការងារ។ |
| ៥ | -មូលដ្ឋានផលិតកម្ម-អាជីវកម្មមួយចំនួនមិនទាន់មានស្មារតីយល់ពីបទប្បញ្ញត្តិច្បាប់ស្តីពីការចុះបញ្ជីសិប្បកម្មឲ្យមានប្រសិទ្ធភាព | -ផ្សព្វផ្សាយច្បាប់នានាទាក់ទងនឹងវិស័យឧស្សាហកម្មសហគ្រាសធុនតូច-មធ្យម និងសិប្បកម្ម។ |

# ផ្នែកទី៤

# ទិសដៅការងារសម្រាប់ឆ្នាំ ២០១៧

## ៤.២. មន្ទីរ អង្គភាពជំនាញ

| ល.រ | សកម្មភាពអាទិភាព | ប្រចាំខែ | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | |
| ២៣).មន្ទីរឧស្សាហកម្ម និងសិប្បកម្ម | | | | | |
| ១ | -ចុះផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម | x | x | x | |
| ២ | -បន្តជំរុញការចុះបញ្ជីស្ថិតិឧស្សាហកម្ម-សិប្បកម្មឲ្យបានល្អប្រសើរជាបន្តបន្ទាប់ | x | x | x | |
| ៣ | -ខិតសំប្រមូលចំណូលពីកម្រៃសេវាប្បញ្ញត្តិ ឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល | x | x | x | |
| ៤ | -យកចិត្តទុកដាក់ដោយសហការជាមួយវិទ្យាស្ថានស្តង់ដារជាតិក្នុងការជួយគាំទ្រផ្នែកបច្ចេកទេសដើម្បីផលិតអង្ករឲ្យមានគុណភាពស្របតាមស្តង់ដារសម្រាប់ការនាំចេញ | x | x | x | |
| ៥ | -យកចិត្តទុកដាក់បំពាក់បំប៉នដល់សិប្បកម្មផលិតចំនីអាហារឲ្យមានអនាម័យ | x | x | x | |
| ៦ | -យកចិត្តទុកដាក់ដល់ឧស្សាហកម្មតូច និងសិប្បកម្មក្នុងការធ្វើអធិការកិច្ចលើការអនុវត្ត(GMP) និង (GHP) | x | x | x | |
| ៧ | -បន្តយកចិត្តទុកដាក់ និងបន្ថែមទៀតក្នុងការជំរុញតាមដាន និងចុះយកគំរូផលិតផលតាមបណ្តាមូលដ្ឋានសិប្បកម្មទៅពិនិត្យអំពីអំពីគុណភាពនៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជាឲ្យបានទៀងទាត់<br>-ធ្វើការសម្របសម្រួលដោះស្រាយបញ្ហាតាមសន្តិវិធី និងបទបញ្ញាត្តិច្បាប់នានា | x | x | x | |
| ៨ | -យកចិត្តទុកដាក់ឲ្យបានហ្មត់ចត់ និងដោយស្មារតីទទួលខុសត្រូវខ្ពស់ មិនរុញរាចំពោះភារកិច្ចការងារ ដើម្បីធានានិរន្តរភាពនៃវប្បធម៌សេវាសាធារណៈ | x | x | x | |

អាស្រ័យដូចបានគោរពជម្រាបជូន ខាងលើសូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

បន្ទាយមានជ័យ , ថ្ងៃទី........... ខែ......... ឆ្នាំ២០១៦

**អ្នកធ្វើរបាយការណ៍**

បានឃើញ និងឯកភាព

បន្ទាយមានជ័យ , ថ្ងៃទី........... ខែ......... ឆ្នាំ២០១៦

**ប្រធានមន្ទីរ**